អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧

កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ កន្លងទៅនេះ លោកកាំង ហ្គេច អ៊ាវ បានសម្រេចជ្រើសរើសសហមេធាវីពីររូបចេញពីបញ្ជីមេធាវីដើម្បីការពាររូបលោកនៅមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺលោកមេធាវី កា សាវុធ និងលោកមេធាវី ហ្វ្រង់ស្វ័រ រូហ្ស (Francois ROUX)។

លោកកាំង ហ្គេច អ៊ាវ បានថ្លែងថាលោកមិនមានលទ្ធភាព និងមធ្យោបាយបង់ថ្លៃសេវាមេធាវីនោះទេ។ ដូច្នេះហើយ មេធាវីទាំងពីររូបត្រូវបានចាត់តាំងដោយអង្គភាពគាំពារការការពារក្តី ដែលជាបន្ទុកចំណាយរបស់អង្គជំនុំជម្រះវិសាមញ្ញ។

លោក កា សាវុធ បានធ្វើជាមេធាវីការពារលោកកាំង ហ្គេច អ៊ាវ អស់រយៈពេល៨ឆ្នាំកន្លងមកហើយ។ គាត់ប្រកបមុខវិជ្ជាជីវៈជាមេធាវីតាំងពីឆ្នាំ១៩៨២ ហើយបានចូលរួមជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាតាំងពីថ្ងៃបង្កើតគណៈមេធាវីដំបូងនៅឆ្នាំ១៩៩៥។ គាត់គឺជាមេធាវីម្នាក់ដែលមានបទពិសោធន៍ក្នុងការការពារក្ដីក្នុងរឿងព្រហ្មទណ្ឌជាច្រើន។

ចំណែកឯលោក ហ្វ្រង់ស្វ័រ រូហ្ស វិញគឺជាមេធាវីសញ្ជាតិបារាំងដែលបានប្រកបមុខវិជ្ជាជីវៈជាមេធាវីនេះជាង៣០ឆ្នាំមកហើយ។ គាត់ធ្លាប់ការពារសំណុំរឿងចំនួនបួនទាក់ទងនឹងបទប្រល័យពូជសាសន៍នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា រួមទាំងការទទួលបានសាលក្រមសម្រេចឱ្យរួចផុតពីបទចោទលើករណីបាជីលីស្មា(Bagilishema)ផង។ គាត់ក៏ជាសមាជិកម្នាក់ក្នុងក្រុមមេធាវីការពារក្តីឱ្យ Zacarais MOUSSAOUI ដែលជាប់ពាក់ព័ន្ធនឹងការវាយប្រហារថ្ងៃទី១១កញ្ញានៅទីក្រុងញូវយ៉កដែរ។ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧នេះ លោក រូហ្ស បានដាក់ពាក្យសុំចុះឈ្មោះទៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា នៅទីក្រុងភ្នំពេញហើយ។ ខណៈពេលដែលពាក្យសុំរបស់លោកកំពុងត្រូវបានគេពិនិត្យពិចារណា លោកមិនអាចនិយាយអ្វីទៅកាន់តុលាការបានទេ ប៉ុន្តែគាត់ត្រូវបានតែងតាំងជាអ្នកពិគ្រោះយោបល់ផ្នែកច្បាប់ដើម្បីជួយក្នុងដំណើរការរៀបចំរឿងក្តីនេះ។

T070801/0019